雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.155

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7652 ថ្ងៃសុក្រ ទី 08 ខែមិថុនា ឆ្នាំ 2018

## លោក លីវ ឈីលីន ប្រធានមន្ទីរពិព័រណ៌អន្តរជាតិខេត្តយូនណាន ពិព័រណ៌ចិន-អាស៊ីខាងត្បូងកាន់តែមានលក្ខណៈបើកទូលាយ និងមានកម្រិតអន្តរជាតូបនីយកម្មកាន់តែខ្ពស់

នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ លោក លីវ ឈីលីន ប្រធានមន្ទីរពិព័រណ៌អន្តរជាតិខេត្តយូនណាន បានផ្ដល់បទសម្ភាសន៍ជាមួយអ្នកកាសែតថា "មានកម្រិតអន្តរជាតូបនីយកម្មកាន់តែខ្ពស់" និង "កាន់តែមានលក្ខណៈបើកទូលាយ" ជាពាក្យគន្លឹះពីររបស់ពិព័រណ៌ចិន-អាស៊ីខាងត្បូងឆ្នាំនេះ។ លោកបានបញ្ជាក់ថា ពិព័រណ៌ចិន-អាស៊ីខាងត្បូងឆ្នាំនេះ មានពន្លាពិព័រណ៌ចំនួន១៩ និងស្ដង់ពិព័រណ៌ប្រមាណ៨៥០០ស្ដង់ សរុបមានផ្ទៃក្រឡា១៩ម៉ឺនម៉ែត្រការ៉េ ដែលមានទំហំធំជាងគេ បើប្រៀបធៀបនឹងពិព័រណ៌មុនៗ។ ជាពិសេសសកម្មភាពអន្តរជាតិចំនួន១៦ នឹងត្រូវរៀបចំក្នុងឱកាសពិព័រណ៌នេះ ដែលមានការចូលរួមពីសហគ្រាសចំនួនជាង៣.០០០។ ក្រៅពីតំបន់ពិព័រណ៌របស់ប្រទេសអាហ្វហ្គានីស្ថាន ដែលជាប្រធានកិត្តិយសនិងប្រទេសមីយ៉ាន់ម៉ា ដែលជាប្រទេសកិត្តិយសនៅមានពន្លាពិព័រណ៌អន្តរជាតិចំនួនប្រាំពីរទៀត ។ គួរបញ្ជាក់ថា តំបន់ពិព័រណ៌របស់សហគ្រាសអន្តរជាតិមានទំហំលើសពី៤០ភាគរយនៃទំហំសរុបនៃតំបន់ពិព័រណ៌នេះ។

លោកបានបន្តទៀតថា គិតមកដល់ពេលនេះ សហគ្រាសជាតិនិងអន្តរជាតិ ដែលមកពីប្រទេសនិងតំបន់ចំនួន៥២លើពិភពលោក ព្រមទាំងខេត្តចំនួន៣១ និងតំបន់ហុងកុង ម៉ាកាវនិងតៃវ៉ាន់របស់ប្រទេសចិនបានចុះឈ្មោះចូលរួមពិព័រណ៌នេះ។ លោកបានបន្ថែមថា យើងខ្ញុំបាននិងកំពុងខិតខំប្រឹងប្រែងដើម្បីបង្កើតវេទិកាស្ដីពីកិច្ចសហប្រតិបត្តិការនិងការផ្លាស់ប្ដូរទ្វេភាគីនិងពហុភាគីដែលមានពាក់ព័ន្ធទៅនឹងផលិតផលមូលធន បច្ចេកទេស និងព័ត៌មានជាដើម ដើម្បីរួមវិភាគទានថ្មីក្នុងការ កសាង "ខ្សែក្រវាត់មួយ និងផ្លូវមួយ"។

តើយើងត្រូវធ្វើដូម្ដេច ដើម្បីធ្វើឱ្យពិព័រណ៌ចិន-អាស៊ីខាងត្បូងនេះកាន់តែមានលក្ខណៈច្នៃប្រឌិតនិងកម្លាំងទាក់ទាញ? លោកលីវ ឈីលីន បានបកស្រាយថា ពិព័រណ៌ចិន-អាស៊ីខាងត្បូងនេះ មិនគ្រាន់តែបានប្រកាន់ខ្ជាប់នូវរូបមន្តទីផ្សារគ្រប់ប្រភេទរួមមានពាណិជ្ជកម្មផលិតផលសេវាកម្មនិងវិនិយោគប៉ុណ្ណោះទេ ថែមទាំងបានជំរុញយ៉ាងសកម្មឱ្យពិព័រណ៌នេះគ្របដណ្ដប់លើវិស័យកាន់តែច្រើននិងកាន់តែមានជំនាញ ។ ក្នុងចំណោមពន្លាពិព័រណ៌ចំនួន១៩នោះ មានជាង៥០ភាគរយ ជាពន្លាពិព័រណ៌ជំនាញ។ ការរៀបចំពន្លាពិព័រណ៌ជំនាញបានជំរុញឱ្យផលិតផលមូលធន និងធនធានមនុស្សមានការផ្លាស់ប្ដូរកាន់តែរលូន។

លោកមានជំនឿថា នាពេលខាងមុខពិព័រណ៌ចិន-អាស៊ីខាងត្បូងនឹងអាចមានឈ្មោះកាន់តែល្បីល្បាញលើពិភពលោក ហើយនឹងអាចពិពណ៌នាឱ្យបានល្អប្រសើរអំពី "រឿងនិទានពិព័រណ៌ចិន-អាស៊ីខាងត្បូង"ដែលមានកម្លាំងទាក់ទាញកាន់ខ្លាំងឡើងៗ៕ **ដោយហាន ឈឹងយាន់**

## វត្ថុតាំងពិព័រណ៍ក្រុមទី១នៃពិព័រណ៍ចិន-អាស៊ីខាងត្បូងត្រូវដឹកជញ្ជូនមកដល់ក្រុងគុនមីង

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ វត្ថុតាំងពិព័រណ៍ក្រុមទី១នៃពិព័រណ៍ចិន-អាស៊ីខាងត្បូងឆ្នាំនេះបានត្រូវដឹកជញ្ជូនមកដល់មជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍អន្តរជាតិបឹងទានឈី ក្រុងគុនមីង ។ វត្ថុតាំងពិព័រណ៍ទាំងនេះ មកពីប្រទេសប៉ាគីស្ថាននិងឥណ្ឌា រួមមានវត្ថុសិប្បកម្មឈើ គ្រឿងសង្ហារិមធ្វើអំពីឈើ វត្ថុសិប្បកម្មស្ពាន់និងវត្ថុសិប្បកម្មថ្មជាដើម។

គួរបញ្ជាក់ថា វត្ថុតាំងពិព័រណ៍ទាំងនេះ ត្រូវនាំចូលពីកំពង់ផែហ្វាងភូថ្មីនៅក្រុងក្វាងចូវ ដោយបានឆ្លងដែនតាមរូបមន្ត "ច្រកតែមួយ" ពោលគឺបំពេញបែបបទឆ្លងដែននៅច្រកអន្តរជាតិនាំចូលរួចហើយ បានត្រូវដឹកជញ្ជូនទៅដល់ក្រុងគុនមីងដោយផ្ទាល់។ តាមការណែនាំពីអ្នកទទួលខុសត្រូវនៃផ្នែកពិនិត្យស្ថានីយនៃការិយាល័យកិច្ចការនៅច្រកឆ្លងដែនស្ថាប័នគយគុនមីងបានឱ្យដឹងថា កាលពីមុនការនាំចូលវត្ថុតាំងពិព័រណ៍នៃពិព័រណ៍ចិន-អាស៊ីខាងត្បូង ត្រូវបានអនុវត្តន៍តាមរបៀបផ្លាស់ច្រកឆ្លងដែន ពោលគឺក្រោយពេលវត្ថុតាំងពិព័រណ៍ត្រូវដឹកជញ្ជូនមកដល់ប្រទេសចិនត្រូវដាក់លើរថយន្តរបស់ស្ថាប័នគយ ដើម្បីដឹកមកដល់ក្រុងគុនមីង។ ចំណែកការដឹកជញ្ជូនវត្ថុតាំងពិព័រណ៍ឆ្នាំនេះបានអនុវត្តន៍តាម "រូបមន្តឆ្លងគយតាមច្រកតែមួយ"។ អ្នកទទួលខុសត្រូវនៃក្រុមហ៊ុនដឹកជញ្ជូនអន្តរជាតិយីធុងខេត្តយូនណាន បានបញ្ជាក់ថា រូបមន្តថ្មីនេះនឹងអាចសំចៃពេលវេលានៃការឆ្លងគយប្រហែល១ភាគ៣ ដែលអាចកាត់បន្ថយនូវដើមទុន៥០០-១.០០០យ៉ាន់សម្រាប់រថយន្តដឹកទំនិញមួយគ្រឿង៕

**ដោយលីវ ជឺយូ**



*កាលពីថ្ងៃទី២៩ ខែឧសភា សមាជិកអ្នករៀបចំពិព័រណ៍បានមកដល់ ទីក្រុងគុនមីង ដើម្បីព្រឹត្តិការណ៍នៃការ រៀបចំពិព័រណ៍ចិន-អាស៊ីខាងត្បូង លើក ទី៥ ដែលត្រូវរៀបចំពីថ្ងៃទី១៤ ដល់ ថ្ងៃទី២០ ខែមិថុនា (រូបថត ដោយ Huang Zhechun )*

